ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៣/២០ - ហ្វ្រោន សីវីស
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ខូន ស៊ីផាន់**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ហ្វ្រោន សីវីស អ៊ិនធើណេសិនណាល**
អាសយដ្ឋាន ៖ ភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ ៖ ០១២ ៨៣១ ១០០ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក ឡាយ ច័ន្ទដារ៉ា ប្រធានគ្រប់គ្រងប្រតិបត្តិការ
២- កញ្ញា គី សារ៉ាណា ប្រធានផ្នែកហិរញ្ញវត្ថុ

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហ្វ្រោន សីវីស អ៊ិនធើណេសិនណាល**
អាសយដ្ឋាន ៖ ភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ ៖ ០៨៦ ៧៥៦ ៦៤២ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក ហាម ស៊ុនរិទ្ធិ មេធាវី
២- លោក ហ៊ាង វណ្ណារ៉ា ហិរញ្ញិកសហព័ន្ធ
៣- លោកស្រី ពេជ្រ សារុនរ័ត្ន ប្រធានសហជីព (មូលដ្ឋាន)
៤- លោក ព្រេម គ្រឹម អនុប្រធានសហជីព (មូលដ្ឋាន)
៥- លោកស្រី ពេជ្រ សីណាត លេខាសហជីព (មូលដ្ឋាន)

៦- លោក មុត សារិន ហិរញ្ញិកសហជីព

៧- លោកស្រី គង់ ជនហានី ទីប្រឹក្សាសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុន ហ្គ្រេន ស៊ីវីស អ៊ិនធើណេសិនណល ទទួលយកថ្នាក់ដឹកនាំសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា នៃក្រុមហ៊ុន ហ្គ្រេន ស៊ីវីស អ៊ិនធើណេសិនណល ចំនួន ៥ នាក់ ដែលមានឈ្មោះ លោកស្រី ពេជ្រ សាលួន, លោក ព្រំម គ្រឹម, លោកស្រី ពេជ្រ ស៊ីលាក, លោក មុត សារិន និង លោកស្រី គង់ ជនហានី។ ភាគីនិយោជក ចំពោះការបញ្ចប់កិច្ចសន្យាការងារនេះ យោងទៅលើក្រុមហ៊ុនមានការកែសម្រួលការផ្គត់ផ្គង់កំលាំងពលកម្ម ដោយសារតម្រូវការរបស់អតិថិជនមានការថយចុះ និងកំហុសឥរិយាបថមួយ ដែលធ្វើឱ្យអតិថិជនមិនសប្បាយចិត្តលើការផ្គត់ផ្គង់សេវាកម្ម ក្នុងកំឡុងពេលដែលក្រុមហ៊ុនកំពុងធ្វើការចរចាលើកិច្ចសន្យាសេវាកម្ម ជាមួយអតិថិជន។

២- កម្មករនិយោជិតទាមទារឱ្យពួកគាត់ទាំង ៥នាក់ ចូលធ្វើការវិញ និងបើកប្រាក់រំលឹក។ និយោជក នៅតែប្រកាន់ជំហរបញ្ជាក់ថា ក្នុងការបញ្ចប់កិច្ចសន្យាការងារមុនថិរវេលាកំណត់នេះ គឺក្រុមហ៊ុនបានហៅបុគ្គលិកដើម្បីជូនដំណឹងមុន អំពីការបញ្ចប់កិច្ចសន្យានេះ ក្រុមហ៊ុនបានគណនាប្រាក់ខែចុងក្រោយ និងប្រាក់សំណងដែលមានកំណត់ក្នុងកិច្ចសន្យាការងារផងដែរ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គ្រេន ស៊ីវីស អ៊ិនធើណេ សិនណល លេខ ០០៤ ម.ក.ប ចុះថ្ងៃសុក្រ ១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

THE ARBITRATION COUNCIL

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ហ្គ្រេន សឺវីស អ៊ិនធើណេសិនណល ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ២ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប បានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារនេះ ទៅតាមនីតិវិធីច្បាប់នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នា។ ចំណុចមិនសះជានេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គ្រេន សឺវីស អ៊ិនធើណេសិនណល លេខ ០០៤ ម.ក.ប ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សា នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ២ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នា ហើយភាគីកម្មករនិយោជិតបានបញ្ចូលចំណុចវិវាទទាំងពីរ ជាចំណុចវិវាទតែមួយ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនឹងពិចារណាចំណុចវិវាទ ១ចំណុចនេះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ ជាកំណត់នៃការផ្តល់ភស្តុតាង និងថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ជាថ្ងៃចុងក្រោយនៃការជំទាស់ភស្តុតាង។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់ ណុប វុធ្នី ជានាយកក្រុមហ៊ុន ហ្គ្រេន សឺវីស អិនធើណេសិនណល ផ្ទេរសិទ្ធិជូន លោក ឡាយ ច័ន្ទធារ៉ា និងកញ្ញា គី សារ៉ាណា ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០។

២- លិខិតរបស់ក្រុមហ៊ុន ហ្គ្រេន សឺវីស អ៊ិនធើណេសិនណល គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាសង្ខេបរឿងក្នុងសំណុំរឿងលេខ ០០៣/២០ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០។

THE ARBITRATION COUNCIL

៣- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ហ្វ្រេន្ទ សុីវីស អិនធើណេសិន-ណល ខប លេខ MOC ៣៩១៨៤០៩០ ពណ.ចបព ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ហ្វ្រេន្ទ សុីវីស អិនធើណេសិនណល ចុះបញ្ជិកាលេខ ៥៩៦ មកប ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧។

៥- លិខិតជូនដំណឹងអំពីបញ្ចប់កិច្ចសន្យាការងារមុនថេរវេលាកំណត់ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

៦- លិខិតរបស់ក្រុមហ៊ុន ហ្វ្រេន្ទ សុីវីស អិនធើណេសិនណល គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើដាក់ឯកសារ និងបញ្ជាក់ពីជំហរបន្ថែម ក្នុងសំណុំរឿងលេខ ០០៣/២០ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។

៧- កិច្ចសន្យាការងាររបស់ឈ្មោះ ពេជ្រ សាលួន, មុត សារិន និង គង់ ផនខានី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩។

៨- កិច្ចសន្យាការងាររបស់ឈ្មោះ ព្រេម ក្រឹម និង ពេជ្រ សុីលាក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩។

៩- លិខិតរបស់ក្រុមហ៊ុន ហ្វ្រេន្ទ សុីវីស អិនធើណេសិនណល គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើដាក់លិខិតបដិសេធលើកស្តុតាងរបស់ភាគីកម្មករនិយោជិតក្នុងសំណុំរឿងលេខ ០០៣/២០ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតតំណាងដោយអាណត្តិ ចុះថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ របស់មេធាវី ហម សុីនរិទ្ធិ គោរពជូន ក្រុមប្រឹក្សាអាជ្ញា-កណ្តាល ស្តីពីតំណាងដោយអាណត្តិ អោយអាណត្តិទាយកឈ្មោះ គង់ ផនដានី, ពេជ្រ សុីលាក, ពេជ្រ សាលួន, ប្រេម ក្រឹម និង មុត សារិន។

២- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ របស់ឈ្មោះ គង់ ផនដានី, ពេជ្រ សុីលាក, ពេជ្រ សាលួន, ប្រេម ក្រឹម និង មុត សារិន ប្រគល់សិទ្ធិជូន មេធាវី ហម សុីនរិទ្ធិ។

៣- លិខិតរបស់មេធាវី ហម សុីនរិទ្ធ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ស្តីពីសារណាការពារឱ្យអាណត្តិទាយកឈ្មោះ គង់ ផនដានី, ពេជ្រ សុីលាក, ពេជ្រ សាលួន, ប្រេម ក្រឹម និង មុត សារិន។

៤- លិខិតបញ្ចូលភស្តុតាងរបស់មេធាវី ហម សុីនរិទ្ធិ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីដាក់ភស្តុតាងសំណុំរឿងលេខ ០០៣/២០ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

៥- លិខិតរបស់សហជីព គោរពជូន អគ្គនាយកក្រុមហ៊ុន ហ្វ្រេន្ទ សុីវីស អិនធើណេសិនណល ស្តីពីជូនដំណឹងស្តីអំពីការបោះឆ្នោតបង្កើតសហជីពប្រចាំក្រុមហ៊ុន ហ្វ្រេន្ទ សុីវីស អិនធើណេសិន ណល ចុះថ្ងៃសៅរ៍ ៦រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

៦- កំណត់ហេតុស្តីពីកិច្ចប្រជុំបង្កើតសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជានៃក្រុមហ៊ុន ហ្គ្រេន សឺរីស អិនធើណេសិនណល ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩។

៧- លិខិតរបស់សហជីព គោរពជូន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ស្តីពីជូនដំណឹងស្តីអំពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំ សហជីពប្រចាំក្រុមហ៊ុន ហ្គ្រេន សឺរីស អិនធើណេសិនណល ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩។

៨- បង្កាន់ដៃទទួលពាក្យស្នើសុំចុះបញ្ជីសហជីពមូលដ្ឋាន ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩។

៩- លិខិតលេខ ០០១/២០ មកប ចុះថ្ងៃពុធ ៦រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថាសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជានៃក្រុមហ៊ុន ហ្គ្រេន សឺរីស អិនធើណេសិនណល ជាអង្គការវិជ្ជាជីវៈមួយបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

១០- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ សហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា នៃក្រុមហ៊ុន ហ្គ្រេន សឺរីស អិនធើណេសិនណល លេខ ០០១/២០ មកប ចុះថ្ងៃពុធ ៦រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។

១១- កិច្ចសន្យាការងាររបស់ ណក់ ឡាយ។

១២- លិខិតជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យាការងារមុនថេរវេលាកំណត់។

១៣- បទបញ្ជាផ្ទៃក្នុងរដ្ឋបាលរបស់សហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជានៃក្រុមហ៊ុន ហ្គ្រេន សឺរីស អិនធើណេសិនណល ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩។

១៤- លក្ខន្តិកៈនៃសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជានៃក្រុមហ៊ុន ហ្គ្រេន សឺរីស អិនធើណេសិនណល បានចុះបញ្ជិកាលេខ ១១៧២០០០២១ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។

១៥- បញ្ញើឆាប់រហ័ស(EMS) ថ្ងៃទី១៩ និងថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩។

១៦- បង្កាន់ដៃទទួលលិខិតជូនដំណឹងស្តីពីជូនដែលត្រូវទទួលបានការការពារ លេខ ០០២ មកប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩។

១៧- ឯកសារភាសាបរទេស។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្គ្រេន សឺរីស អ៊ិនធើណេសិនណល លេខ ០០៤ ម.ក.ប ចុះថ្ងៃសុក្រ ១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ្គ្រេន សឺរីស អ៊ិនធើណេសិនណល ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ប្រេ្កាន ស៊ីវីស អ៊ិនធើណេសិនណល លេខ ០០១-០១/២០ មកប ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០១៩។

យ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០១៩ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០២០ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០។

**អនុហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

ក្រុមហ៊ុន ប្រេ្កាន ស៊ីវីស អ៊ិនធើណេសិនណល គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងផ្នែកសេវាកម្មផ្គត់ផ្គង់កម្លាំងពលកម្ម។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតសរុបចំនួន ៥៧នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ប្រេ្កាន ស៊ីវីស អ៊ិនធើណេសិនណល)*។

**ចំណុចវិវាទទី១ និងទី២ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកទទួលយកកម្មករនិយោជិត ពេជ្រ សាលួន, ព្រោម គ្រីម, ពេជ្រ ស៊ីលាភ, មុត សារិន និង គង់ ជនឋានី ចូលធ្វើការវិញ និងបើករំលឹកប្រាក់ឈ្នួលជូនពួកគាត់**

- ភាគីនិយោជកបានលើកឡើងថា ចំណុចវិវាទនេះ គឺជាវិវាទបុគ្គល ពីព្រោះ បន្ទាប់ពីផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ៥នាក់ ខាងលើហើយ ក្រុមហ៊ុនប្រព្រឹត្តិទៅជាធម្មតា និងពុំមានប៉ះពាល់ដល់ដំណើរការក្រុមហ៊ុនឡើយ។
- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកទទួលយកកម្មករនិយោជិត ពេជ្រ សាលួន, ព្រោម គ្រីម, ពេជ្រ ស៊ីលាភ, មុត សារិន និង គង់ ជនឋានី ឱ្យចូលធ្វើការវិញ និងបើករំលឹកប្រាក់ឈ្នួលជូនកម្មករនិយោជិត ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ។
- ភាគីទាំងពីរបានទទួលស្គាល់ថា៖
  - កម្មករនិយោជិត ពេជ្រ សាលួន ចូលធ្វើការងារដំបូងនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ជាកម្មករនិយោជិតផ្នែកអនាម័យ ដោយទទួលបានប្រាក់ឈ្នួល ១៦៨០០រៀល ក្នុងមួយថ្ងៃ។
  - កម្មករនិយោជិត ព្រោម គ្រីម ចូលធ្វើការដំបូងនៅឆ្នាំ២០១២ ជាកម្មករនិយោជិតផ្នែកសំណង់ បន្ទាប់មកត្រូវបានផ្លាស់ប្តូរទៅផ្នែកផ្សារដែក ដោយទទួលបានប្រាក់ឈ្នួល ២៩៣០០រៀល ក្នុងមួយថ្ងៃ។
  - កម្មករនិយោជិត ពេជ្រ ស៊ីលាភ ចូលធ្វើការដំបូងនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦ ដោយទទួលបានប្រាក់ឈ្នួល ១៦៨០០ រៀល ក្នុងមួយថ្ងៃ។

THE ARBITRATION COUNCIL

- ០ កម្មករនិយោជិត មុត សារិន ចូលធ្វើការដំបូងនៅឆ្នាំ២០១៦ ដោយទទួលបានប្រាក់ឈ្នួល ១៩៨០០រៀល ក្នុងមួយថ្ងៃ។
- ០ កម្មករនិយោជិត គង់ ផនហានី ចូលធ្វើការដំបូងនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ ដោយទទួលបានប្រាក់ឈ្នួល ១៦៨០០រៀល ក្នុងមួយថ្ងៃ។
- ០ ជាការអនុវត្តនៅក្នុងក្រុមហ៊ុន និយោជកបានអនុវត្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ខែម្តងៗ ជាមួយកម្មករនិយោជិត។ កម្មករនិយោជិតទាំង ៥នាក់ ខាងលើ គឺមានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ៣ខែម្តងៗ។
- ០ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩ និយោជកបានរំលាយកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ខែចុងក្រោយ របស់កម្មករនិយោជិតទាំង ៥នាក់ ខាងលើ មុនកាលកំណត់។

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា៖
  - ០ យោងតាមប្រការ ៨.១ នៃកិច្ចសន្យាការងារ និងមាត្រា ៧៣ នៃច្បាប់ស្តីពីការងារ កិច្ចសន្យាការងារមានថិរវេលាកំណត់អាចរំលាយមុនកាលកំណត់បាន តែក្នុងករណីមានការព្រមព្រៀងពីភាគីទាំងសងខាងនៃកិច្ចសន្យាតែប៉ុណ្ណោះ។
  - ០ និយោជកពុំមានមូលហេតុសមរម្យដើម្បីបញ្ឈប់កម្មករនិយោជិតទេ ព្រោះកម្មករនិយោជិតមិនបានប្រព្រឹត្តិកំហុសអ្វីនោះទេ។
  - ០ ការបញ្ឈប់នេះ គឺមានការរើសអើងសហជីព និងមិនត្រឹមត្រូវតាមនីតិវិធីច្បាប់ ព្រោះកម្មករនិយោជិតទាំង ៥នាក់ ខាងលើ គឺជាថ្នាក់ដឹកនាំសហជីព និងជាបេក្ខភាពឈរឈ្មោះជាថ្នាក់ដឹកនាំសហជីព។ ការបញ្ឈប់នេះ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបង្កើតសហជីពរបស់កម្មករនិយោជិត ពីព្រោះអស់រយៈពេល ១២ឆ្នាំហើយ ក្រុមហ៊ុននេះមិនទាន់មានសហជីពទេ។
  - ០ កម្មករនិយោជិតនៅតែចង់បន្តធ្វើការងារនៅក្រុមហ៊ុននេះ ពីព្រោះ កន្លែងធ្វើការមានចម្ងាយជិតផ្ទះរបស់គាត់ ហើយគាត់ស្រលាញ់ការងាររបស់គាត់។

- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា៖
  - ០ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩ កម្មករនិយោជិតបានជូនដំណឹងទៅលោក លី សុភី តាមរយៈប្រៃសណីយ៍កម្ពុជា អំពីការរៀបចំបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពដែលត្រូវធ្វើនៅថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៩។
  - ០ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ កម្មករនិយោជិតបានជូនដំណឹងអំពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទៅលោក លី សុភី តាមរយៈប្រៃសណីយ៍កម្ពុជា។
  - ០ កន្លងមក នៅពេលដែលភាគីម្ខាងទៀតបានទទួលបញ្ញើរបស់ប្រៃសណីយ៍កម្ពុជាហើយ មន្ត្រីរបស់ប្រៃសណីយ៍កម្ពុជានឹងមិនជូនដំណឹងដល់ភាគីដែលផ្ញើនោះទេ ហើយក្នុងករណីនេះ មន្ត្រីរបស់ប្រៃសណីយ៍កម្ពុជាមិនបានផ្តល់ដំណឹងមកកម្មករនិយោជិតដែលជាអ្នកផ្ញើនោះទេ។
  - ០ លោក លី សុភី គឺជាអ្នកចាត់ចែងការងារឱ្យកម្មករនិយោជិតធ្វើនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប ហើយមានតំណែងជាប្រធានគ្រប់គ្រងការងាររបស់ពួកគាត់នៅព្រលានយន្តហោះ។
  - ០ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៩ និយោជកបានកោះហៅកម្មករនិយោជិតមកប្រជុំ និងបានសួរនាំអំពីបំណងនៃការបង្កើតសហជីពនេះ ហើយនៅថ្ងៃបន្ទាប់ និយោជកបានកោះហៅកម្មករ

និយោជិតមកប្រជុំជាលើកទី២ និងបានប្រាប់កម្មករនិយោជិតឱ្យខិតខំធ្វើការងារ ហើយការងារពួកគាត់ គឺមិនទាក់ទងនឹងអតិថិជននោះទេ។

- នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ភាគីកម្មករនិយោជិតបានដាក់ពាក្យសុំចុះបញ្ជីការសហជីពទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប។
- នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩ និយោជកបានកោះហៅកម្មករនិយោជិត ពេជ្រ សាលួន, គង់ ជនឋានី និង ព្រេម ក្រឹម មកប្រជុំជាលើកទី៣ នៅម៉ោង ៣ និង ៣០ នាទីរសៀល និងកម្មករនិយោជិត ពេជ្រ ស៊ីលាក និង មុត សារិន នៅម៉ោង ៤ និង ៣០ នាទី រសៀល អំពីការមិនរើសអើងសហជីព ហើយបញ្ឈប់កម្មករនិយោជិតទាំង ៥នាក់នេះ ដោយមូលហេតុទាក់ទងនឹងការធ្លាក់ចុះនៃភ្ញៀវទេសចរណ៍ដែលធ្វើដំណើរតាមរយៈអាកាសយានដ្ឋានអន្តរជាតិសៀមរាប ប៉ុន្តែក្រោយមក និយោជកបានជ្រើសរើសកម្មករនិយោជិតថ្មី ៣នាក់ បន្ថែមទៀត។

- ភាគីនិយោជកបញ្ជាក់ថា គាត់មិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា៖
  - សម្រាប់ឆ្នាំ២០២០នេះ និយោជកមិនអាចធានាស្ថេរភាពការងាររបស់កម្មករនិយោជិតបានទេ ពីព្រោះអាកាសយានដ្ឋានអន្តរជាតិសៀមរាប អាចនឹងកាត់បន្ថយសេវាកម្មពលកម្មពីនិយោជក ដោយមូលហេតុថា ភ្ញៀវទេសចរណ៍ ដែលធ្វើដំណើរតាមរយៈអាកាសយានដ្ឋានអន្តរជាតិសៀមរាប មានការធ្លាក់ចុះ។
  - ចំពោះការប្រជុំនៅថ្ងៃទី២៧ និង២៨ ខែតុលា ឆ្នាំ២០១៩ គឺជាការប្រជុំធម្មតាអំពីស្ថានភាពពាណិជ្ជកម្ម និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងដើម្បីសួរនាំស្ថានភាពការងារ និងរៀបចំផែនការការងាររបស់កម្មករនិយោជិតក្នុងឆ្នាំ២០២០ បន្តទៀត។
  - នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩ និយោជកបានជូនដំណឹងអំពីការរំលាយកិច្ចសន្យាការងារមុនកាលកំណត់ ដោយមូលហេតុទាក់ទងនឹងការធ្លាក់ចុះនៃភ្ញៀវទេសចរណ៍ដែលធ្វើដំណើរតាមរយៈអាកាសយានដ្ឋានអន្តរជាតិសៀមរាប ដោយនិយោជកពុំបានដឹងអំពីការបង្កើតសហជីពទេ។ ក្រោយពីបានបញ្ឈប់កម្មករនិយោជិតទាំង ៥នាក់ ខាងលើហើយ និយោជកក៏បានបញ្ឈប់កម្មករនិយោជិត ២នាក់ នៃផ្នែកផ្សេងទៀតដែរ។
  - និយោជកមិនបានដឹងអំពីសមាសភាពថ្នាក់ដឹកនាំសហជីពទេ នៅពេលដែលបញ្ឈប់កម្មករនិយោជិត ពីព្រោះកម្មករនិយោជិតមិនបានជូនដំណឹងដល់និយោជកអំពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ដូចមានចែងក្នុងមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពទេ ដោយកម្មករនិយោជិតបានជូនដំណឹងទៅលោក លី សុភី ដែលមិនមែនជាកម្មករនិយោជិត ឬថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន ហ្គ្រោន ស៊ីវីស អ៊ិនធើណេសិនណល ឡើយ។
  - កម្មករនិយោជិតថ្មីទាំង ៣នាក់ គឺជាកម្មករនិយោជិតដែលធ្វើការដាច់ដោយឡែកពីផ្នែករបស់កម្មករនិយោជិតទាំង ៥នាក់ ខាងលើទេ។

- ភាគីកម្មករនិយោជិតបានប្រានចោលការលើកឡើងរបស់ភាគីនិយោជក ដោយបញ្ជាក់ថា លិខិតដែលកម្មករនិយោជិតចុះហត្ថលេខានៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩ គ្រាន់តែជាលិខិតចុះវត្តមានប្រជុំតែ

THE ARBITRATION COUNCIL

ប៉ុណ្ណោះ ប៉ុន្តែ និយោជកបានបំពេញកំណត់សម្គាល់ការជូនដំណឹងរំលាយកិច្ចសន្យាការងារបន្ថែម បន្ទាប់ពីកិច្ចប្រជុំ។

- ភាគីនិយោជកមានជំហរបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ៥នាក់ ខាងលើ ដោយសម្រេចទូទាត់សំណងជូនកម្មករនិយោជិតនូវប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារស្របតាមច្បាប់ស្តីពីការងារ។
- ចំណែក ភាគីកម្មករនិយោជិតនៅតែរក្សាជំហរទាមទារសុំចូលធ្វើការវិញ ដោយមិនទាមទារឱ្យនិយោជកគិតប្រាក់បំណាច់ផ្សេងៗនៅពេលបញ្ឈប់ពីការងារទេ។
- ឯកសាររបស់កម្មករនិយោជិតមានដូចជា ៖
    - ញត្តិគាំទ្ររបស់ភាគីកម្មករនិយោជិត ចំនួន ៤០នាក់ ដែលជាកម្មករនិយោជិតនៃក្រុមហ៊ុន ហ្វ្រោន សីរីស អ៊ិនធើណេសិនណល ជាមួយនឹងនិយោជក។
    - លិខិតជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពប្រចាំក្រុមហ៊ុន ហ្វ្រោន សីរីស អ៊ិនធើណេសិនណល ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩ ដែលមានរាយនាមបេក្ខជនឈរឈ្មោះ ចំនួន ៧នាក់ មានដូចជា៖ មុត សារិន, គង់ ជនហាំនី, ព្រេម ក្រឹម, ពេជ្រ សាលួន, ពេជ្រ ស៊ីលាក, ខ្យង យ៉ុន និង សន ណាង។
    - លិខិតជូនដំណឹងស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពប្រចាំក្រុមហ៊ុន ហ្វ្រោន សីរីស អ៊ិនធើណេសិនណល ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩ ដែលមានកម្មករនិយោជិត ពេជ្រ ស៊ីលាក ជាប្រធាន, ព្រេម ក្រឹម ជាអនុប្រធាន, ពេជ្រ ស៊ីលាក ជាលេខាធិការ និង មុត សារិន ជាហិរញ្ញឹក។
    - បង្កាន់ដៃទទួលពាក្យស្នើសុំចុះបញ្ជី របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨។
    - សាលកប័ត្រផ្ញើសេវារបស់សេវាប្រៃសណីយ៍កម្ពុជា ដែលកម្មករនិយោជិតផ្ញើទៅលោក លី សុភី ដែលមានអាសយដ្ឋាននៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩។
    - សាលកប័ត្រផ្ញើសេវារបស់សេវាប្រៃសណីយ៍កម្ពុជាដែលកម្មករនិយោជិតផ្ញើទៅលោក លី សុភី ដែលមានអាសយដ្ឋាននៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩។
    - បង្កាន់ដៃទទួលលិខិតជូនដំណឹងស្តីពីជនដែលត្រូវទទួលបានការការពារពិសេស របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩។

**ហេតុផលនៃសេចក្តីសម្រេច ៖**

**ចំណុចវិវាទទី១ និងទី២ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកទទួលយកកម្មករនិយោជិត ពេជ្រ សាលួន, ព្រេម ក្រឹម, ពេជ្រ ស៊ីលាក, មុត សារិន និង គង់ ជនហាំនី ឱ្យចូលធ្វើការវិញ និងបើករំលឹកប្រាក់ឈ្នួលជូនកម្មករនិយោជិតចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ**

មុននឹងពិចារណាការទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការទាមទារខាងលើនេះ គឺជាវិវាទការងាររួម ឬវិវាទបុគ្គល?

THE ARBITRATION COUNCIL

ប្រការ ៣២ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា៖ *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវសម្រេចសេចក្តីលើវិវាទការងាររួមដែលដាក់មកខ្លួនដោយយោងទៅតាមមាត្រា ៣០៩ នៃច្បាប់ស្តីពីការងារ"*។

តាមរយៈប្រការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការដោះស្រាយតែវិវាទការងាររួមប៉ុណ្ណោះ។

បន្ថែមពីលើនេះ ដោយអនុលោមទៅតាមជំពូក១២ ផ្នែកទី២ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ក្រុមប្រឹក្សាអាជ្ញាកណ្តាល មានយុត្តាធិការក្នុងការសម្រេចតែលើវិវាទការងាររួមតែប៉ុណ្ណោះ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៩៤/០៤-អេ អាយ អេ ហេតុផលនៃចំណុចវិវាទទី៦, លេខ៨១/០៦-ហុង អ៊ី ហេតុផលនៃចំណុចវិវាទទី១)*។

ជាគោលការណ៍ អធិការកិច្ចការងារ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចក្នុងការសម្រេចថា តើវិវាទណាមួយជាវិវាទបុគ្គល ឬវិវាទការងាររួម មុនពេលបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដូច្នេះ ជាធម្មតា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងគោរពតាមការសម្រេចរបស់អធិការកិច្ចការងារ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រសិនបើគ្មានហេតុផលជំទាស់ច្បាស់លាស់នោះទេ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលនៃចំណុចវិវាទទី៤, លេខ ៤១/០៤-មីកាសា, លេខ ០៧/០៥-កូកាកូឡា ហេតុផលនៃចំណុចវិវាទទី១ និងទី២, លេខ ៤៥/០៧-វិលសិន ហេតុផលនៃចំណុចវិវាទទី៤, លេខ ១៣/០៨-តេក៉ាតិច្ស ហេតុផលនៃចំណុចវិវាទទី២, លេខ ១៤/១១-ជី អេច ជី ហេតុផលនៃចំណុចវិវាទទី២ និងលេខ ២៥៣/១៤-តួតាល់ កម្ពុជា)*

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៥/០៧-វិល សិន ហេតុផលនៃចំណុចវិវាទទី៤ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានថា៖ *"រាល់ការទាមទារទាំងអស់នៅក្នុងរបាយការណ៍មិនសះជារបស់ក្រសួងការងារ គឺជាវិវាទរួម។ ដោយសារតែភាគីនិយោជកបានធ្វើការជំទាស់ទៅលើការសន្និដ្ឋាននេះ និយោជកមានបន្ទុកផ្តល់ភស្តុតាងបញ្ជាក់អំពីអំណះអំណាងរបស់ខ្លួន"*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកបានអះអាងថា វិវាទរវាងកម្មករនិយោជិត ពេជ្រ សាលួន, ព្រេម ក្រឹម, ពេជ្រ ស៊ីលាក, មុត សារិន និង គង់ ជនឋានី និងនិយោជក មិនមែនជាវិវាទការងាររួមនោះទេ គឺជាវិវាទបុគ្គល។

មាត្រា ៣០២ នៃច្បាប់ស្តីពីការងារចែងថា៖ *"វិវាទការងាររួម គឺជាវិវាទដែលកើតឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់ នឹងបុគ្គលិករបស់ខ្លួនមួយចំនួន អំពីរឿងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករនិយោជិត ហើយការវិវាទនេះ អាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម"*។

ផ្អែកលើមាត្រា ៣០២ នៃច្បាប់ស្តីពីការងារ ដើម្បីកំណត់ថា វិវាទមួយជាវិវាទការងាររួម ត្រូវបំពេញជាចាំបាច់ តាមលក្ខខណ្ឌបីយ៉ាងនៃវិវាទការងាររួម ដូចមានចែងក្នុងច្បាប់ស្តីការងារតាមមាត្រា ៣០២ គឺ៖

១- ជាវិវាទរវាងបុគ្គលិកមួយចំនួន និងនិយោជកម្នាក់ ឬច្រើននាក់

២-បញ្ហានៃវិវាទទាក់ទង និងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការទទួលស្គាល់អង្គការវិជ្ជាជីវៈ ឬបញ្ហានៃទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិត និង

THE ARBITRATION COUNCIL

៣-វិវាទនេះអាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម។

នៅក្នុងករណីនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ ពីព្រោះ ការទាមទារនេះ គឺមានពាក់ព័ន្ធផ្ទាល់នឹងកម្មករនិយោជិតចំនួន ៥នាក់ហើយ លើសពីនេះ យោងតាមញត្តិគាំទ្ររបស់ភាគីកម្មករនិយោជិត មានកម្មករនិយោជិតចំនួន ៤០នាក់ ដែលជាកម្មករនិយោជិតនៃក្រុមហ៊ុន ហ្វ្រេន សីវីស អ៊ិនធើណេសិនណល ជាមួយនឹងនិយោជក បានទាមទារចំណុចវិវាទនេះ។

ចំពោះលក្ខខណ្ឌទី២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ត្រូវបានបំពេញដែរ ដោយហេតុថា វិវាទនេះ ទាក់ទងនឹងការផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិត មុនកាលកំណត់ ដែលជាបញ្ហាទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិត ពោលគឺ ទាក់ទងនឹងការទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិតទាំងអស់នោះ ចូលធ្វើការវិញ។

ចំពោះលក្ខខណ្ឌទី៣ យោងតាមពាក្យបណ្តឹងនិងញត្តិគាំទ្រ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានពាក្យបណ្តឹង ដែលមានឈ្មោះ និងស្នាមមេដៃកម្មករនិយោជិតសរុប ចំនួន ៤០នាក់ ដើម្បីទាមទារចំណុចវិវាទនេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតចំនួន ៤០នាក់ ដែលជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ អាចធ្វើសកម្មភាពរួមគ្នាណាមួយដែលអាចនាំឱ្យមានភាពរាំងស្ទះដល់ដំណើរការរបស់ក្រុមហ៊ុន ឬអាចបណ្តាលឱ្យក្រុមហ៊ុនប្រព្រឹត្តទៅពុំបានស្រួលនៅពេលអនាគត ប្រសិនបើចំណុចវិវាទនេះមិនត្រូវបានដោះស្រាយ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុចវិវាទនៃបណ្តឹងទាមទាររបស់កម្មករនិយោជិត ពេជ្រ សាលួន, ព្រេម ក្រឹម, ពេជ្រ ស៊ីលាភ, មុត សារិន និង គង់ ជនឋានី នៅក្នុងសំណុំរឿងនេះ គឺជាវិវាទការងាររួម ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការ ក្នុងការសម្រេចសេចក្តី។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាទៅលើការទាមទាររបស់កម្មករនិយោជិត ពេជ្រ សាលួន, ព្រេម ក្រឹម, ពេជ្រ ស៊ីលាភ, មុត សារិន និង គង់ ជនឋានី ដូចខាងក្រោម ៖

ភាគីទាំងពីរទទួលស្គាល់ថា ករណីនេះ និយោជកបានបញ្ឈប់កម្មករនិយោជិតទាំង ៥នាក់ ខាងលើ មុនកាលកំណត់នៃកិច្ចសន្យាការងារ។ ភាគីកម្មករនិយោជិតលើកឡើងថា កម្មករនិយោជិតទាំង ៥នាក់នេះ គឺជាថ្នាក់ដឹកនាំសហជីព និងបេក្ខជនឈរឈ្មោះបោះឆ្នោតសហជីព ហើយការបញ្ឈប់នេះ គឺមិនត្រឹមត្រូវតាមនីតិវិធីច្បាប់។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើកម្មករនិយោជិត ពេជ្រ សាលួន, ព្រេម ក្រឹម, ពេជ្រ ស៊ីលាភ, មុត សារិន និង គង់ ជនឋានី ជាកម្មករនិយោជិតដែលអាចទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ ដែរ ឬទេ ?

កថាខណ្ឌទី១ មាត្រា ៤៣ នៃច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ បានចែងថា៖ "*រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួន អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ...*"។

មាត្រា ៦៧ នៃច្បាប់ស្តីពីសហជីព ដដែល ចែងថា៖ "*កម្មករ និយោជិតទាំងអស់ដែលជាបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំគ្រប់គ្រងសហជីព ទទួលបាននូវការការពារពីការរងគ្រោះ និងការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ។ ការការពារនេះមានរយៈពេល ៤៥(សែសិបប្រាំ)ថ្ងៃ មុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥(សែសិបប្រាំ)ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះ*

THE ARBITRATION COUNCIL

*មិនបានជាប់ឆ្នោត ។ ដើម្បីទទួលបានការការពារពិសេសនេះ សហជីពត្រូវជូនដំណឹងទៅនិយោជក និងចម្លងជូនក្រសួងទទួលបន្ទុកវិស័យការងារអំពីបេក្ខភាពនេះ តាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាបានការ។ និយោជកត្រូវអនុវត្តបទប្បញ្ញត្តិនេះតែម្តងគត់ នៅរៀងរាល់ពេលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព។*

*ចាប់តាំងពីពេលដាក់ពាក្យសុំចុះបញ្ជី សហជីពទាំងអស់ដែលជាស្ថាបនិក ឬកម្មករនិយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីពនេះ ក្នុងពេលកំពុងស្នើសុំចុះបញ្ជីត្រូវទទួលបានការការពារដូចគ្នានឹងប្រតិភូបុគ្គលិកដែរ។ ការការពារនេះមានរយៈពេលរហូតដល់ ៣០(សាមសិប)ថ្ងៃ ក្រោយកាលបរិច្ឆេទដែលក្រសួងទទួលបន្ទុកវិស័យការងារបញ្ជាក់អំពីបញ្ជិកាសហជីព...*"។

យោងតាមសំណុំរឿងលេខ ១៦៩/១៦-ម៉ានីង គួរី ហ្គាមេន អ៊ិនធើប្រាយ ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា៖ "*យោងតាមមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីព ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដើម្បីទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ កម្មករនិយោជិតត្រូវបំពេញលក្ខខណ្ឌ ចំនួន ០៣ គឺ **លក្ខខណ្ឌទី១** ៖ កម្មករនិយោជិត គឺជាកម្មករនិយោជិតដែលទទួលបាននូវការការពារពិសេស, **លក្ខខណ្ឌទី២** ៖ ការបញ្ឈប់ពីការងារស្ថិតនៅក្នុងពេលដែលពួកគេបានទទួលនូវការការពារ (រយៈពេល ៤៥ថ្ងៃ មុនថ្ងៃបោះឆ្នោតសហជីព និងត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ថ្ងៃ ក្រោយថ្ងៃបោះឆ្នោតសហជីព) និង**លក្ខខណ្ឌទី៣** ៖ កម្មករនិយោជិតត្រូវជូនដំណឹងដល់និយោជក និងចម្លងទៅក្រសួងទទួលបន្ទុកវិស័យការងារ អំពីឈ្មោះអ្នកដែលត្រូវទទួលការការពារតាមគ្រប់មធ្យោបាយដែលទុកជាបានការ (សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៧០/១៦-ចាយូ (ខេមបូឌា) អឹមកែរីល មេនូហ្វេកធឺរីង ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១ និងលេខ ១៨៨/១៦-ហ្គ្រីន សាំមីត (ខេមបូឌា) លីមីធីត ហេតុផលនៃចំណុចវិវាទទី២)*"។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលក្នុងសំណុំរឿងខាងមុនៗលើដែរ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើកម្មករនិយោជិត ពេជ្រ សាលួន, ព្រុម គ្រីម, ពេជ្រ ស៊ីលាក, មុត សារិន និង គង់ ជនឋានី បានបំពេញគ្រប់លក្ខខណ្ឌទាំង ៣ ខាងលើនេះ ដែរ ឬទេ?

**លក្ខខណ្ឌទី១ ៖ កម្មករនិយោជិតជាប្រភេទកម្មករនិយោជិតដែលទទួលបានការការពារ**

យោងតាមលិខិតរបស់កម្មករនិយោជិតដែលមានកម្មវត្ថុ៖ ជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពប្រចាំក្រុមហ៊ុន ហ្វ្រេន ស៊ីវីស អ៊ិនធើណេសិនណល ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានបេក្ខជនឈរឈ្មោះបោះឆ្នោត និងស្ថាបនិកសរុប ចំនួន ៧នាក់ ក្នុងនោះរួមមានឈ្មោះ ១. មុត សារិន, ២. គង់ ជនឋានី, ៣. ព្រុម គ្រីម, ៤. ពេជ្រ សាលួន, ៥. ពេជ្រ ស៊ីលាក, ៦. ខ្យង យ៉ុន និង៧. សន ណាង។ យោងតាមលទ្ធផលនៃការបោះឆ្នោតសហជីព កម្មករនិយោជិត ពេជ្រ សាលួន, ព្រុម គ្រីម និងពេជ្រ ស៊ីលាក បានជាប់ជាថ្នាក់ដឹកនាំសហជីព ចំណែកកម្មករនិយោជិត មុត សារិន និង គង់ ជនឋានី គឺជាបេក្ខជនឈរឈ្មោះបោះឆ្នោត។ ហេតុនេះ យោងតាមមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពខាងលើ កម្មករនិយោជិតទាំង ៥នាក់ខាងលើ គឺជាប្រភេទកម្មករនិយោជិតដែលទទួលបានការការពារពីការបញ្ឈប់ពីការងារ។ ដូចនេះលក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី២ ៖ ការបញ្ឈប់ពីការងារស្ថិតនៅក្នុងពេលដែលកម្មករនិយោជិតបានទទួលនូវការការពារ**

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨ ភាគីកម្មករនិយោជិតបានដាក់ពាក្យសុំចុះបញ្ជីការសហជីព ទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប។ ភាគីនេះ និយោជកបានបញ្ឈប់កម្មករនិយោជិត ពេជ្រ

សាលួន, ព្រេម គ្រឹម, ពេជ្រ ស៊ីលាក, មុត សារិន និង គង់ ជនឋានី នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ហេតុនេះ យោងតាមការបកស្រាយលើមាត្រា ៦៧ នៃច្បាប់ស្ដីពីសហជីពខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា និយោជកបានបញ្ឈប់កម្មករនិយោជិតទាំង ៥នាក់ ខាងលើ នៅក្នុងរយៈពេលដែលគាត់ត្រូវទទួលបានការការពារពិសេស ពោលគឺនៅក្នុងអំឡុងពេលស្នើសុំបញ្ជិកាសហជីព។ ដូចនេះ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

**លក្ខខណ្ឌទី៣ ៖ កម្មករនិយោជិតបានជូនដំណឹងដល់និយោជក និងចម្លងជូនទៅក្រសួងទទួលបន្ទុកវិស័យការងារ អំពីឈ្មោះកម្មករនិយោជិត ដែលត្រូវទទួលបានការការពារតាមគ្រប់មធ្យោបាយ ដែលទុកជាបានការ**

ករណីនេះ ភាគីកម្មករនិយោជិតលើកឡើងថា នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩ កម្មករនិយោជិតបានជូនដំណឹងទៅលោក លី សុគី អំពីការរៀបចំបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ដែលត្រូវធ្វើនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩ តាមរយៈប្រៃសណីយ៍កម្ពុជា។ ហើយនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ភាគីកម្មករនិយោជិតក៏បានផ្ញើលិខិតជូនដំណឹងអំពីលទ្ធផលនៃការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទៅឱ្យលោក លី សុគី តាមរយៈប្រៃសណីយ៍កម្ពុជា ផងដែរ។ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ដដែលនេះ ភាគីកម្មករនិយោជិតបានបំពេញកាតព្វកិច្ចជូនដំណឹងទៅមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តសៀមរាប អំពីឈ្មោះបេក្ខជនដែលទទួលបានការងារពារពិសេសរួចហើយដែរ។ តែយ៉ាងណាមិញ ភាគីនិយោជកបានជំទាស់ថា លោក លី សុគី គឺជាប្រធានផ្នែកសេវាកម្មថែទាំ (maintenance service manager) នៃអាកាសយានដ្ឋានអន្តរជាតិសៀមរាប មិនមែនជានិយោជិត ឬជាថ្នាក់ដឹកនាំ ដែលតំណាងឱ្យក្រុមហ៊ុន ហ្វ្រេន្ទ សឺវីស អ៊ិនធើណេសិនណល ទេ។ ហេតុនេះ និយោជកមិនបានដឹងអំពីការជូនដំណឹងពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពនេះទេ។ យ៉ាងណាមិញ ភាគីកម្មករនិយោជិតបានអះអាងថា លោក លី សុគី គឺជាអ្នកចាត់ចែងការងារឱ្យពួកគាត់ធ្វើនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប ហើយមានតួនាទីគ្រប់គ្រងការងារផ្ទាល់របស់ពួកគាត់។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីដែលធ្វើការអះអាង ឬចោទប្រកាន់ គឺមានបន្ទុកកស្ដុតាង *(សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៧៩/០៥-អេភើហ្គើ, លេខ ១០១/០៨-ជីឌីអ៊ឹម ហេតុផលនៃចំណុចវិវាទទី១ និងទី២, លេខ ១៦៨/០៩-ទីកថ្លា ផ្លាហ្សា ហេតុផលនៃចំណុចវិវាទទី២, លេខ ១១៥/១០-ជី-ហ្វម៉ូស ហេតុផលនៃចំណុចវិវាទទី១៨, លេខ ១៤៨/១១-ជាយ យ៉ាំង, និងលេខ ២៧៦/១៥-មិត្តភាព ហ្គាមិន ហេតុផលនៃចំណុចវិវាទទី១)*។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនៗ បានបដិសេធការទាមទារ ឬច្រានចោលការអះអាងរបស់ភាគីវិវាទ ប្រសិនបើភាគីដែលធ្វើការទាមទារ ឬធ្វើការអះអាងនោះ មិនមានមូលដ្ឋានគ្រប់គ្រាន់ ឬភស្តុតាងជាក់លាក់ ដើម្បីគាំទ្រនូវការទាមទារ ឬការអះអាងរបស់ខ្លួន *(សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៦៣/០៤-សាញ វ៉ែល ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៩/០៦-សៅធ៍បាយ ហេតុផលនៃចំណុចវិវាទទី៥, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៤, លេខ ៥១/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣, និងលេខ ០៣២/១៦-អ៊ីជើនិធី ក្លឹបិល ស្ពតជីង (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១)*។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្ដាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ក្រៅពីការអះអាង ភាគីកម្មករនិយោជិតមិនបានផ្ដល់ភស្តុតាងជាក់លាក់ណាមួយ ដើម្បីគាំទ្រអំណះអំណាងដែលថា លោក លី សុគី គឺជានិយោជិត ឬ តំណាងឱ្យនិយោជកនៃក្រុមហ៊ុន ហ្វ្រេន្ទ សឺវីស អ៊ិនធើណេសិនណល នោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់

ឃើញថា ភាគីកម្មករនិយោជិតមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការជូនដំណឹងទៅនិយោជក ពីឈ្មោះកម្មករនិយោជិតដែលទទួលបានការការពារតាមគ្រប់មធ្យោបាយ ដែលទុកជាបានការ ស្របតាមមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពនោះទេ។ ដូចនេះ លក្ខខណ្ឌទី៣ មិនត្រូវបានបំពេញទេ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិត ពេជ្រ សាលួន , ព្រេម គ្រីម, ពេជ្រ ស៊ីលាភ, មុត សារិន និង គង់ ជនឋានី មិនបានបំពេញនូវលក្ខខណ្ឌទាំង៣ ដើម្បីទទួលបានការការពារពិសេសទេ ពោលគឺភាគីកម្មករនិយោជិតមិនបានបំពេញកាតព្វកិច្ចនៃលក្ខខណ្ឌទី៣ នោះទេ។ ហេតុនេះ កម្មករនិយោជិត ពេជ្រ សាលួន, ព្រេម គ្រីម, ពេជ្រ ស៊ីលាភ, មុត សារិន និង គង់ ជនឋានី មិនទទួលបានការការពារពិសេសដែលមានចែងក្នុងមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពឡើយ។

**ជាបន្ត ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចទទួលយកកម្មករនិយោជិតទាំង ៥នាក់ ខាងលើ ចូលធ្វើការវិញ និងសងប្រាក់រំលឹក ដែរ ឬទេ?**

កថាខណ្ឌទី៣ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"ការរំលាយកិច្ចសន្យាដោយឆន្ទៈរបស់និយោជកតែឯកឯង មុនកាលកំណត់...បើកសិទ្ធិឱ្យកម្មករនិយោជិតទទួលជម្ងឺចិត្ត ដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវបានទទួលរហូតដល់ពេលចប់កិច្ចសន្យា"*។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី ៣ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា និយោជកអាចរំលាយកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលារបស់កម្មករនិយោជិតណាម្នាក់ ដោយឆន្ទៈផ្ទាល់របស់និយោជកមុនកាលកំណត់បាន ដោយកម្មករនិយោជិតនោះមានសិទ្ធិទទួលបានជម្ងឺចិត្តពីនិយោជក ដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលដែលត្រូវទទួល រហូតដល់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាដល់កាលផុតកំណត់ *(សូមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៤២/១៣-ឌី & អិល អាល់ជីមេត (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី១, លេខ ២៤៣/១៣-បឌី យើដ ហ្សេសិន វ៉ែរ ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី២, និងលេខ ២៤៥/១៣-ហ្វីស ហ្គារ័ន្ត អីកែរីល (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី១)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាល នៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ និយោជកបានបញ្ឈប់កម្មករនិយោជិតទាំង ៥នាក់ខាងលើ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩ ពោលគឺ និយោជកបានបញ្ឈប់ពួកគាត់ មុនពេលកិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់ពួកគាត់ដល់កាលផុតកំណត់។ យោងតាមកថាខណ្ឌទី៣ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារខាងលើ និយោជកមានសិទ្ធិបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់កម្មករនិយោជិត មុនកាលកំណត់បាន ដោយនិយោជកត្រូវផ្តល់នូវប្រាក់ជម្ងឺចិត្តជូនកម្មករនិយោជិត ដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលដែលគាត់ត្រូវបានទទួល រហូតដល់ពេលចប់កិច្ចសន្យាការងារ និងទូទាត់ប្រាក់បំណាច់ផ្សេងៗស្របតាមច្បាប់ស្តីពីការងារ ជូនពួកគាត់។ ករណីនេះ ភាគីនិយោជកមានជំហរបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ៥នាក់ខាងលើ ដោយសម្រេចទូទាត់សំណងជូនកម្មករនិយោជិត នូវប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារស្របតាមច្បាប់ស្តីពីការងារ ដោយមិនព្រមទទួលយកពួកគាត់ចូលធ្វើការវិញទេ។ ហេតុនេះ យោងតាមកថាខណ្ឌទី៣ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារខាងលើ និយោជកមិនមានកាតព្វកិច្ចទទួលយកកម្មករនិយោជិតទាំង ៥នាក់នេះ ចូលធ្វើការវិញទេ ប៉ុន្តែនិយោជកត្រូវទូទាត់ប្រាក់បំណាច់ផ្សេងៗស្របតាមច្បាប់ស្តីពីការងារជូនពួកគាត់។ នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកទទួលយកពួកគាត់ចូលធ្វើការវិញ ហើយមិន

THE ARBITRATION COUNCIL

បានទាមទារឱ្យនិយោជកគិតប្រាក់បំណាច់ផ្សេងៗ នៅពេលបញ្ឈប់ពីការងារទេ។ ហេតុនេះ ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាអំពីការទូទាត់ប្រាក់បំណាច់ផ្សេងៗ នោះទេ។សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកទទួលយកកម្មករនិយោជិត ពេជ្រ សាលួន, ព្រេម គ្រឹម, ពេជ្រ ស៊ីលាក, មុត សារិន និង គង់ ជនហានី ឱ្យចូលធ្វើការវិញ និងបើករំលឹកប្រាក់ឈ្នួលជូនកម្មករនិយោជិតចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ និងទី២៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកទទួលយកកម្មករនិយោជិត ពេជ្រ សាលួន, ព្រេម គ្រឹម, ពេជ្រ ស៊ីលាក, មុត សារិន និង គង់ ជនហានី ឱ្យចូលធ្វើការវិញ និងបើករំលឹកប្រាក់ឈ្នួលជូនកម្មករនិយោជិតចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ----------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **ទួន ស៊ីផាន់**

ហត្ថលេខា ៖----------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ----------------------------------

THE ARBITRATION COUNCIL